មជ្ឈមណ្ឌលឯកសារកម្ពុជា

## មាគ៌ានយោបាយ

# «បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ»

**ដោយៈ ចាន់ ប្រាថ្នា**

(ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១)

មាគ៌ានយោបាយស្តីពី«បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ» ត្រូវបានជនជាប់ចោទ នួន ជា ផ្តល់សក្ខីកម្មថា ជាខ្លឹមសារពិតនៃការធ្វើបដិវត្តន៍កម្ពុជា ។[១] នៅក្នុងឋានៈខ្លួនជាអ្នកទទួលបន្ទុករៀបចំមាគ៌ានយោបាយជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីរបស់បក្សជាមួយ ប៉ុល ពត[២] ជនជាប់ចោទ នួន ជា បានឲ្យនិយមន័យយ៉ាងច្បាស់ថាៈ ពាក្យ«ប្រជាជាតិ» គឺកំចាត់ឥទ្ធិពលរបស់អាណានិគម ពាក់កណ្តាលអាណានិគម ។[៣] ចំណែកឯ «ប្រជាធិបតេយ្យ» គឺកម្ចាត់ឥទ្ធិពលរបស់ពួកសក្តិភូមិម្ចាស់ដី ។[៤] បន្ថែមលើនេះ ជនជាប់ចោទ នួន ជា បានចង្អុលបង្ហាញយ៉ាងច្បាស់ថា បរទេស កម្មែលដែលនៅសល់ កម្មែលបរទេសដែលនៅប្រើអំណាចអាជ្ញាមកលើប្រជាជនខ្មែរ គឺជាសត្រូវរបស់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យដែលត្រូវផ្តុះលាង ។[៥] ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា មាគ៌ានយោបាយជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីនេះ ត្រូវបានមហាសន្និបាទបក្សលើកទី១ដែលប្រារព្ធឡើងក្នុងឆ្នាំ១៩៦០ បានឯកភាពឲ្យយកមកអនុវត្ត ។[៦] ជនជាប់ចោទ នួន ជា បានបញ្ជាក់បន្ថែមថា ក្រោយពីបក្សមានមាគ៌ានយោបាយជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីនេះមក បដិវត្តន៍កម្ពុជាចេះតែចម្រើនជាលំដាប់ៗឡើងមករហូត ។[៧]

នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ គឺជាថ្ងៃទីពីរដែលអង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការសួរដេញដោលលើភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុស្តីពី «ប្រវត្តិរបស់បក្សកុម្មុយនិស្តកម្ពុជា» និង «តួនាទីរបស់ជនជាប់ម្នាក់ៗមុនរបបកម្ពុជាប្រជាធិបតេយ្យ»ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ ។ នៅក្នុងអំឡុងពេលសវនាការនេះ លោកស្រីចៅក្រមអន្តរជាតិ ស៊ីលវៀ ខាតវ៉្រាយត៍ បានសួរពីតួនាទី

---

១ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះជំណាក់កាលដំបូង ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ (ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១)ឯកសារលេខ E1/17.1 ទំព័រទី១៣ កថាខណ្ឌទី៣ ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/court/16269

២ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១០ កថាខណ្ឌទី ១៦ ។

៣ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១៣ កថាខណ្ឌទី ៤ ។

៤ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១៣ កថាខណ្ឌទី ៥ ។

៥ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១៣ កថាខណ្ឌទី៩ ដល់១១ ។

៦ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១៥ កថាខណ្ឌទី១៤ ដល់១៥ ។

៧ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១៥ កថាខណ្ឌទី១ ដល់២ ។

របស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមបង្កើតគោលនយោបាយជាយុទ្ធសាស្ត្ររបស់បក្សពលករកម្ពុជា ឬបក្សកុម្មុយនិស្តកម្ពុជា ។[៨] ឆ្លើយតបទៅនឹងសំណួរនេះ ជនជាប់ចោទ នួន ជា បានឆ្លើយយ៉ាងលម្អិតពីប្រវត្តិនៃការបង្កើតមាគ៌ានយោបាយយុទ្ធសាស្ត្រ និងតួនាទីរបស់ខ្លួនក្នុងការបង្កើតមាគ៌ានយោបាយយុទ្ធសាស្ត្រនេះ ។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបលើសក្ខីកម្មរបស់ជនជាប់ចោទ នួន ជា ដែលបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការបង្កើតមាគ៌ានយោបាយជាយុទ្ធសាស្ត្រនេះ ៖

*[ជនជាប់ចោទ នួន ជា បានលើកឡើងថា នៅចន្លោះឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៦០ បក្សមិនទាន់មានមាគ៌ានយោបាយជាយុទ្ធសាស្ត្រ និងជាយុទ្ធវិធីឯករាជ្យខ្លួនឯងនៅឡើយ គឺនៅអាស្រ័យពឹងពាក់លើវៀតណាមទាំងអស់ ធ្វើអ្វីៗត្រូវមានសារាចរណែនាំពីហាណូយទើបអាចអនុវត្តបាន ។ ឃើញសភាពបែបនេះ ទូ សាមុត បានស្នើសុំឲ្យ ខ្លួន(នួន ជា) និង ប៉ុល ពត ត្រៀមរៀបចំមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីរបស់បក្សជាបណ្តើរៗឲ្យហើយ ដើម្បីអាចរំដោះបក្សរបស់ខ្លួនរួចផុតពីការដឹកនាំបញ្ជារបស់វៀតណាម ។ ជនជាប់ចោទ នួន ជា បានបន្ថែមថា ក្រោយពីបានទទួលនូវសេចក្តីណែនាំពី ទូ សាមុត ខ្លួន និង ប៉ុល ពត បានទទួលភារៈកិច្ចរៀបចំមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីរបស់បក្ស ។ ក្នុងការរៀបចំនូវមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីនេះគឺ ប៉ុល ពត ទទួលបន្ទុកក្តាប់សភាពការណ៍នៅតាមទីក្រុង ចំណែកខ្លួនជាអ្នកទទួលបន្ទុកទាក់ទងជាមួយកម្មាភិបាលចាស់ៗ ដែលនៅសល់ពីសម័យក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ខ្លួនទាក់ទងបាន ភូមិភាគពាយព្យ ភូមិភាគនិរតី និងបាត់ដំបង ចំណែកឯ ប៉ុល ពត ទាក់ទងបានកម្មាភិបាលភូមិភាគបូព៌ាគឺ សោ ភឹម ។ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា ក្រោយពីទាក់ទងបានកម្មាភិបាលទាំងនេះ ខ្លួនបានស្នើឲ្យស៊ើបសួរពីសភាពការណ៍នៅតាមជនបទ ចំណែកឯ ប៉ុល ពត ស៊ើបសួរសភាពការណ៍នៅទីក្រុង ។ ក្រោយពីការស៊ើបសួរសភាពការណ៍នេះ ខ្លួនយល់ថានៅជនបទប្រជាជនភាគច្រើន៨៥ភាគរយជាកសិករក្រីក្រដែលត្រូវបានជិះជាន់ដោយ មេភូមិ មេឃុំ ប៉ូលីស ទាហ៊ាន និងអ្នកមាន ។ល។ រីឯ ប៉ុល ពត ក្តាប់បានសភាពការណ៍ថា មានមន្ត្រីរាជការតូចតាចមួយចំនួនដែលមានជីវៈភាពខ្វះខាត ។ ជនជាប់ចោទ នួន ជា បានសង្កត់ធ្ងន់ថា កសិករក្រីក្រ និងមន្ត្រីរាជការដែលមានឋានៈតូចតាចទាំងនេះដែលនឹងត្រូវមើលឃើញជាកំលាំងដែលត្រូវទាក់ទាញ (**“នេះយើងត្រូវឃើញកំលាំង”**) ។ ជនជាប់ចោទ នួន ជា បានលើកឡើងថា មុននឹងធ្វើមាគ៌ានយោបាយ បក្សបានធ្វើការវិភាគអំពីធាតុពិតនៃសង្គមកម្ពុជានៅពេលនោះ ។ បន្ទាប់ពីសិក្សាអំពីសភាពការណ៍នៅពេលនោះ បក្សពិនិត្យឃើញថា “សង្គមកម្ពុជាគឺជាសង្គមពាក់កណ្តាលអាណានិគម ហើយពាក់កណ្តាលសក្តិភូមិ” ។ ជនជាប់*

---

៨ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី៩ កថាខណ្ឌទី១៩ ដល់២៨ ។

ប៉ោទូរូបនេះបានលើកឡើងថា “សង្គមកម្ពុជាជាសង្គមពាក់កណ្ដាលអាណានិគម ពីព្រោះវានៅមានកម្អែលអាណានិគមនៅឡើយវាមិនទាន់ឯករាជ្យស្វ័យសាធនៅឡើយទេ ហើយជាសង្គមពាក់កណ្ដាលសក្តិភូមិ ពីព្រោះវាមានរបបនាយទុនហើយវាមិនមែនសក្តិភូមិទាំងស្រុងទេ” ។ ដូចនេះបើធាតុពិតនៃសង្គមកម្ពុជាជាសង្គមពាក់កណ្ដាលអាណានិគម ពាក់កណ្ដាលសក្តិភូមិ គឺត្រូវធ្វើបដិវត្តន៍ជាតិប្រជាធិបតេយ្យ ។ ជនដាប់ប៉ោទ នួន ជា បានបញ្ជាក់ថា ធាតុពិតរបស់បដិវត្តន៍កម្ពុជានៅពេលនោះគឺជា“**បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ**” ។ ពាក្យ“**បដិវត្តន៍ប្រជាជាតិ**” **មានន័យថា កម្ចាត់ឥទ្ធិពលរបស់អាណានិគម ពាក់កណ្ដាលអាណានិគម ។** ចំណែកឯពាក្យ“**ប្រជាធិបតេយ្យ**”**គឺកម្ចាត់ឥទ្ធិពលរបស់ពួកសក្តិភូមិម្ចាស់ដី អ្នករកស៊ីប៉ុលបណ្ដាល់ ចងការ** ។ដូចនេះសត្រូវរបស់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យគឺ “បរទេសកម្អែលបរទេស កំអែលបរទេសដែលនៅប្រើអំណាចអាជ្ញាមកលើប្រជាជនខ្មែរ នេះគឺជាសត្រូវដែលត្រូវដុះលាង ។ ឯពាក់កណ្ដាលសក្តិភូមិគឺ ទាមទារឲ្យកសិករតស៊ូបន្ថយឈ្នួលស្រែ ការប្រាក់ ប៉ុលបណ្ដាក់” ។ ប៉ុន្តែជនដាប់ប៉ោទូរូបនេះបានបញ្ជាក់ថា“មិនមែនយកមនុស្សជាសត្រូវទេខ្ញុំសូមជម្រាប គឺយកការប្រព្រឹត្តរបស់គេជាសត្រូវ” ។ ជនដាប់ប៉ោទ នួន ជា បានបញ្ជាក់ថា ដើម្បីកម្ចាត់សត្រូវទាំងនោះ កម្លាំងបដិវត្តន៍របស់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យត្រូវមានប្រភពចេញពី កសិករក្រ កសិករកណ្ដាលថ្នាក់ក្រោម ក្រោមសម្ពន្ធ័ភាពរបស់កម្មករកសិករ... ។ ជនដាប់ប៉ោទូរូបនេះបានបន្ថែមថា នៅក្នុងការកសាងកម្លាំងបដិវត្តន៍បក្សបានបង្កើតមាគ៌ាយុទ្ធវិធីដែលជាទូទៅហៅថា“មាគ៌ារណៈសិរ្សរួបរួមជាតិ” ដោយរណៈសិរ្សរួមរួបរួមជាតិនេះ ធ្វើការប្រមូលកំលាំងគ្រប់ជនជាតិទាំងអស់ដែលមានស្មារតីជាតិ ស្មារតីស្នេហាប្រជាជន មិនរើសអើងពីអតីតកាល មិនថាជនជាតិភាគតិច មិនថាជនជាតិភាគច្រើន ចូលមករួបរួមគ្នាជាកម្លាំងមហាសាមគ្គីជាតិដើម្បីតស៊ូកំចាត់របបពាក់កណ្ដាលអាណានិគម ពាក់កណ្ដាលសក្តិភូមិ ។ ចំណែកវិធីសាស្ត្រនៃការធ្វើបដិវត្តន៍ គឺចាប់ផ្ដើមធ្វើពីចុងកាត់មាត់ញក ពាលដាលទៅទីប្រជុំជន ទៅតាមទីរួមស្រុក គឺប្រៀបដូចជាដំណក់ប្រេង ដែលកាលនោះខ្លួនបានប្រើពាក្យថា “ធ្វើបដិវត្តន៍របៀបដំណក់ប្រេង” ដោយធ្វើការតស៊ូ ដោយស្របច្បាប់ ពាក់កណ្ដាលស្របច្បាប់ មិនស្របច្បាប់ តស៊ូទាំងនយោបាយ តស៊ូទាំងសេដ្ឋកិច្ច តស៊ូទាំងវប្បធម៌ ហើយបើចាំបាច់ត្រូវតស៊ូទាំងអាវុធនិងនយោបាយរួមផ្សំគ្នា ។ ជនដាប់ប៉ោទ នួន ជា បានបញ្ជាក់ថា ចលនានៃការតស៊ូដើម្បីសម្រេចបានបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ គឺស្ថិតនៅក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ក្រោមពាក្យស្លោក តស៊ូយូរអង្វែង លំបាកវេទនា ខ្លួនទីពឹងខ្លួន ខ្លួនសម្រេចវាសនាជាតិខ្លួនដោយខ្លួនឯង ។ នៅចុងបញ្ចប់ ជនដាប់ប៉ោទ នួន ជា បានបញ្ជាក់ថា ក្រោយ

ពីបក្សមានមាគ៌ានយោបាយដាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីនេះ ចលនាបដិវត្តន៍កម្ពុជា ក៏ចេះតែមានការរីកចម្រើនដាលំដាប់រហូតដល់វាយឈ្នះរបបលន់ នល់ ឆ្នាំ១៩៧៥...] ។[៩]

នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ (ដីកានេះត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) បានរៀបរាប់ផងដែរអំពីអង្គហេតុពាក់ព័ន្ធនឹងការបោសសម្អាត(នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ទៅលើ វណ្ណៈសក្តិភូមិ និងអ្នកដែលធ្លាប់មានអតីតដាប់ពាក់ព័ន្ធនឹងរបប លន់ នល់ ។ តាមរយៈដីកានេះបញ្ជាក់ឲ្យឃើញថា ជនរងគ្រោះមួយចំនួនធំត្រូវបានគេសម្លាប់ ក្រោយពេលដែលគេដឹងថាជនរងគ្រោះទាំងនោះធ្លាប់ធ្វើ ឬមានសាច់ញាតិធ្លាប់ធ្វើការនៅក្នុងរបប លន់ នល់ ឬជនរងគ្រោះទាំងនោះត្រូវបានគេគិតថាជាពួកសក្តិភូមិ ។ ជាក់ស្តែង កថាខណ្ឌទី២០៥នៃដីកានេះ បញ្ជាក់ថា "...សហគេហក្រុមស៊ើបអង្កេតត្រូវបានគេប្តឹងអំពីអំពើទាក់ទងការប្រឆាំងនឹងក្រុម ជនជាតិចាម ជនជាតិវៀតណាម និងពុទ្ធសាសនិក ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសារណៈរដ្ឋខ្មែរ(ដូចជាមន្ត្រី យោធា និងក្រុមគ្រួសាររបស់ពួកគេ) ។ អំពើទាំងនេះត្រូវបានប្រព្រឹត្តដោយបក្សកុម្មុយនិស្តកម្ពុជានៅទីកន្លែងផ្សេងគ្នានៃប្រទេសកម្ពុជាចាប់ពីមុនឆ្នាំ១៩៧៥ ដែលជាដំណាក់កាលដំបូងនៃការត្រួតត្រារបស់បក្សកុម្មុយនិស្តកម្ពុជាទៅលើទឹកដីមួយផ្នែក និងបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" ។[១០] កថាខណ្ឌទី៤៧៩នៃដីកានេះបានលើកឡើងផងដែរថា "ប្រជាជនត្រូវបានចាប់ខ្លួនដោយចោទថាជាខ្មាំង ដែលសំដៅដល់អ្នកដែលមានការពាក់ព័ន្ធនឹងរបប លន់ នល់ ទាំងតាមការជាក់ស្តែងឬតាមការស្មាន ជាខ្មែរស ជាពួកសក្តិភូមិ ជាពួកមូលធន ជាសេអ៊ីអា ឬកាហ្សេប ..." ។[១១] ច្បាស់ជាងនេះទៅទៀត កថាខណ្ឌទី៦៩៥នៃដីកាដដែលនេះបានបញ្ជាក់ថា "អតីតឈ្លបម្នាក់បានបញ្ជាក់ថា ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយនៅក្នុងភូមិច្រកសង្កែ ឃុំស្វាយដុក ដែលពេលនោះប្រធានគណៈឃុំស្វាយដុក ឈ្មោះ (កោលលុប) បានស្នើឲ្យមេភូមិទាំងអស់ធ្វើការប្រមូលប្រវត្តិរូបរបស់ប្រជាជនទាំងអស់ដែលជម្លៀសមកពីភ្នំពេញ ។ ប្រជាជនទាំងនោះត្រូវបានបែងចែកជាពីរប្រភេទគឺ "មនុស្សធម្មតា កសិករ" និង "ទាហាន ឬរដ្ឋការរបស់របប លន់នល់ ពួកសក្តិភូមិ" ។ ប្រជាជនដែលស្ថិតនៅក្នុងប្រភេទទីពីរ(ប្រហែល៧០០នាក់) ត្រូវបានគេចង វាយកញ្ចឹងកដោយប្រើដំ

---

៩ សូមមើលសក្ខីកម្មរបស់ នួន ជា លម្អិតនៅក្នុងប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ពីទំព័រទី១០ ដល់១៦ ។

១០ ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ (ដីកាដំណោះស្រាយ) ឯកសារលេខ D427 កថាខណ្ឌទី២០៥ ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/court/14885

១១ ដីកាដំណោះស្រាយ កថាខណ្ឌទី ៤៧៩ ។

បងប្អូនស្រី និងបន្ទាប់មកកប់ក្នុងដីនៅកន្លែងមួយហៅថា ព្រៃទទឹង ដែលស្ថិតនៅចម្ងាយប្រហែល១គីឡូម៉ែត្រ ខាងលិចព្រៃវិស្រុត» ។[១២]

ដូចនេះអ្វីដែលសំខាន់ តើមាគ៌ានយោបាយស្តីពី«បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ» ត្រូវបានបក្សកុម្មុយនិស្តកម្ពុជា យកមកអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ជនជាប់ចោទ នួន ជា បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា ការប្តូរឈ្មោះរបស់បក្សពី «បក្សពលករកម្ពុជា» មកជា«បក្សកុម្មុយនិស្តកម្ពុជា» គឺដើម្បីជៀសវាងការភាន់ច្រឡំរវាង«បក្សពលករវៀតណាម» និង«បក្សពលករកម្ពុជា» ថាមានប្រភពតែមួយ ។ ជនជាប់ចោទ នួន ជា បានបញ្ជាក់យ៉ាងច្បាស់ថា ទោះបីមានការប្តូរឈ្មោះបក្សដូចនេះក្តី តែមាគ៌ានយោបាយ មាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីមិនមានការកែប្រែឡើយ ពោល«បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ» ដែលត្រូវបានប្រើប្រាស់ដោយបក្សពលករកម្ពុជា ត្រូវបានយកមកអនុវត្តនៅក្នុងបក្សកុម្មុយនិស្តកម្ពុជាដោយស្វ័យប្រវត្តិ ។[១៣] នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ជនជាប់ចោទ នួន ជា បានផ្តល់សក្ខីកម្មបន្ថែមថា «ដូច្នោះ ក្នុងរយៈពេលតាំងពីធ្វើមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីមក យើងបានតស៊ូវាយឈ្លះ ចក្រពត្តិអាមេរិច ពួក លន់ នល់..» ។[១៤] បន្ថែមលើនេះ កថាខណ្ឌទី២០៨ នៃដីកាដំណោះស្រាយ បានបញ្ជាក់ថា«វិធានការដែលបានធ្វើឡើងប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺកើតចេញមកពីគោលនយោបាយដែលមានមុនឆ្នាំ ១៩៧៥ មកម្ល៉េះ ហើយបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ ១៩៧៩.» ។[១៥]

ដូច្នេះ **«ប្រសិនបើ»** មាគ៌ានយោបាយស្តីពី«បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ» ត្រូវបានបក្សកុម្មុយនិស្តកម្ពុជា យកមកអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះឧក្រិដ្ឋកម្មដែលបានកើតចេញពីការបោសសម្អាត «វណ្ណៈសក្តិភូមិ និងជនទាំងឡាយណាដែលបក្សយល់ថាជាកម្មែលអាណានិគម» នៅក្នុងរបបនោះ គឺមិនមែនជារឿងចៃដន្យដែលកើតឡើង ដោយមេដឹកនាំខ្មែរក្រហមមិនបានដឹងឡើយ ។ ពោលមាគ៌ានយោបាយក្នុងការបោសសម្អាតសង្គមពាក់កណ្តាលអាណានិគម និងពាក់កណ្តាលសក្តិភូមិ ត្រូវបានមេដឹកនាំខ្មែរក្រហមរៀបចំ និងអនុវត្តតាំងតែពីឆ្នាំ១៩៦០មកម្ល៉េះ ។

ចប់

---

១២ ដីកាដំណោះស្រាយ កថាខណ្ឌទី ៦៩៥ ។

១៣ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះដំណាក់កាលដំបូង ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ឯកសារលេខ E1/16.1 ទំព័រទី៥៤ ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/court/16268 ។

១៤ ប្រតិចារឹកថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ទំព័រទី១៥ កថាខណ្ឌទី២៣ ។

១៥ ដីកាដំណោះស្រាយ កថាខណ្ឌទី ២០៨ ។